## ព័ត៌មានសម្រាប់ជនរងគ្រោះទូទាំងរដ្ឋ

ការិយាល័យ Massachusetts ទទួលបន្ទុក ជំនួយជនរងគ្រោះ
ក្រុមប្រឹក្សាជំនួយជនរងគ្រោះ និងសាក្សី
(617) 586-1340

ផ្នែកសំណង និងជំនួយជនរងគ្រោះ
ការិយាល័យអគ្គមេធាវី
(617) 727-2200 លេខបន្ត 2160

ការិល័យមេធាវីអាមេរិក
កម្មវិធីជនរងគ្រោះ និងសាក្សី
(617) 748-3100

នាយកដ្ឋានសេវាព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌ
អង្គភាពសេវាជនរងគ្រោះ (DCJIS)
(617) 660-4690 ឬ (617) 660-4606 (TTY)

នាយកដ្ឋានកែប្រែ Massachusetts
អង្គភាពសេវាជនរងគ្រោះ
(978) 369-3618
លេខឥតគិតថ្លៃ (866) 6VICTIM (866-684-2846)

ក្រុមប្រឹក្សា Massachusetts Parole Board
អង្គភាពសេវាជនរងគ្រោះ
(508) 650-4500 ឬ (888) 298-6272

ក្រុមប្រឹក្សាបញ្ជីជនល្មើសផ្លូវភេទ
អង្គភាពសេវាជនរងគ្រោះ
(978) 740-6440
ទូរស័ព្ទឥតគិតថ្លៃ (800) 93MEGAN (800-936-3426)

នាយកដ្ឋានសេវាយុវជន (DYS)
អង្គភាពសេវាជនរងគ្រោះ
(617) 727-7575

សេវាព្យួរទោសមានលក្ខខណ្ឌ Massachusetts
អង្គភាពសេវាជនរងគ្រោះ
(617) 727-5300

Massachusetts Office For Victim Assistance
MOVA
Victim & Witness Assistance Board

### សេចក្តីថ្លែងបេសកកម្ម

បេសកកម្មរបស់ការិយាល័យជំនួយជនរងគ្រោះ (MOVA) គឺដើម្បីផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះ និងសាក្សីទាំងអស់នៃឧក្រិដ្ឋកម្មនៅក្នុងសហធន។ MOVA ខិតខំធានាឱ្យមានលទ្ធភាពទទួលបានសេវាសមធម៌នៅទូទាំងសហធន ដែលបំពេញបាននូវតម្រូវការពិសេសរបស់អ្នកទទួលរងផលប៉ះពាល់ដោយសារបទឧក្រិដ្ឋ តាមរយៈការអភិវឌ្ឍន៍គោលនយោបាយដែលមានព័ត៌មានអំពីអ្នករួចផុតពីអំពើហិង្សា ការគ្រប់គ្រងមូលនិធិ ការបណ្តុះបណ្តាល និងជំនួយបុគ្គល។

### ការិយាល័យជំនួយជនរងគ្រោះ Massachusetts

ក្រុមប្រឹក្សាជំនួយជនរងគ្រោះ និងសាក្សី
One Ashburton Place, Suite 1310
Boston, MA 02108
ទូរសព្ទ៖ (617) 586-1340
ទូរសារ៖ (617) 586-1367
www.mass.gov/mova

ការផ្សព្វផ្សាយនេះទទួលបានជំនួយមួយផ្នែកតាមរយៈជំនួយឥតសំណង VOCA មកពី OVC, OJP, US DOJ ។ ទស្សនៈ លទ្ធផលរកឃើញ និងការសន្និដ្ឋាន ឬអនុសាសន៍ផ្សេងៗដែលបង្ហាញជូននៅក្នុងការផ្សព្វផ្សាយនេះគឺជាទស្សនៈ លទ្ធផលរកឃើញ និងការសន្និដ្ឋាន ឬអនុសាសន៍របស់ការិយាល័យជំនួយជនរងគ្រោះ Massachusetts ហើយមិនសុទ្ធតែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ DOJ ឬ OJP, OVC ឡើយ។

## កម្មវិធីជំនួយសាក្សីជនរងគ្រោះ

ការិយាល័យមេធាវីប្រចាំតំបន់សម្រាប់ខោនធីនីមួយៗ ក្នុងរដ្ឋ Massachusetts និងការិយាល័យអគ្គមេធាវី មានកម្មវិធីជំនួយសាក្សីជនរងគ្រោះ ដើម្បីជួយដល់ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មក្នុងអំឡុងពេលចោទប្រកាន់នៃសំណុំរឿង។ សម្រាប់ព័ត៌មាន និងជំនួយអំពីឧក្រិដ្ឋកម្មដែលអ្នកគឺជាជនរងគ្រោះ សូមទូរស័ព្ទទៅកម្មវិធីជំនួយសាក្សីជនរងគ្រោះនៅក្នុងខោនធីដែលឧក្រិដ្ឋកម្មបានកើតឡើង។

**ការិយាល័យអគ្គមេធាវី Attorney General's**

| | |
|---|---|
| **Criminal Bureau** | (617) 727-2200 |
| **ខោនធី Berkshire** | (413) 443-5951 |
| **ខោនធី Bristol** | (508) 997-0711 |
| **ខោនធី Cape & Islands Barnstable, Dukes & Nantucket** | (508) 362-8113 |
| **ខោនធី Essex** | (978) 745-6610 |
| **ខោនធី Hampden** | (413) 747-1000 |
| **ខោនធី Middlesex** | (781) 897-8300 |
| **ខោនធី Norfolk** | (781) 830-4800 |
| **Northwestern ខោនធី Franklin** | (413) 774-3186 |
| **ខោនធី Hampshire** | (413) 586-9225 |
| **ខោនធី Plymouth** | (508) 584-8120 |
| **ខោនធី Suffolk** | (617) 619-4000 |
| **ខោនធី Worcester** | (508) 755-8601 |

KHMER 0322

# សំណើច្បាប់ស្តីពីសិទ្ធិជនរងគ្រោះ

## MASSACHUSETTS

ស្វែងយល់អំពីសិទ្ធិរបស់អ្នកក្នុងនាមជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម

Massachusetts Office For Victim Assistance
MOVA
Victim & Witness Assistance Board

# សំណើច្បាប់ស្ដីពីសិទ្ធិជនរងគ្រោះ MASSACHUSETTS

សំណើច្បាប់ស្ដីពីសិទ្ធិជនរងគ្រោះ* ត្រូវបានរៀបចំឡើងដើម្បីធានាថា ជនរងគ្រោះដោយសារឧក្រិដ្ឋកម្ម និងសាក្សីត្រូវបានជូនដំណឹង មានវត្តមាន និងត្រូវបានកោះហៅចូលរួមសវនការក្នុងដំណាក់កាលសំខាន់ៗនៅក្នុងបញ្ហាព្រហ្មទណ្ឌពាក់ព័ន្ធនឹងរឿងក្ដីរបស់ខ្លួន។

សិទ្ធិជាសារវន្ត និងជាមូលដ្ឋានទាំងនេះមានគោលដៅផ្ដល់ឱ្យជនរងគ្រោះ និងអ្នករួចផុតពីអំពើហិង្សានូវតួនាទីដ៏សំខាន់នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ *អ្នកចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជូនព្រះរាជអាជ្ញា ឬអ្នកតស៊ូមតិជនរងគ្រោះដែលត្រូវបានកំណត់ឱ្យធ្វើការជាមួយអ្នក នូវព័ត៌មានទំនាក់ទំនងរបស់អ្នក ដើម្បីអាចឱ្យពួកគេធានាថា អ្នកទទួលបានអត្ថប្រយោជន៍ពីសិទ្ធិដែលអ្នកមាន។*

** សម្រាប់បញ្ជីសិទ្ធិពេញលេញរបស់អ្នក សូមមើលសំណើច្បាប់ស្ដីពីសិទ្ធិជនរងគ្រោះ (M.G.L.c.258B.)*

## សិទ្ធិ និងសេវាកម្មជនរងគ្រោះនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

*អ្នកមានសិទ្ធិ...*

» ទទួលបានការជូនដំណឹងអំពីរបៀបដំណើរការសំណុំរឿងព្រហ្មទណ្ឌតាមរយៈ ប្រព័ន្ធ តួនាទីរបស់អ្នកនៅក្នុងដំណើរព្រមទាំងចំណុចរំពឹងទុកពីអ្នក និងមូលហេតុ។

» ទទួលបានការជូនដំណឹងអំពីសិទ្ធិ និងសេវាដែលជនរងគ្រោះ និងសាក្សីមាននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

» ទទួលបានការជូនដំណឹងអំពីរបៀបទទួលបាន សេវាសង្គម ការគាំទ្រសហគមន៍ និងជំនួយហិរញ្ញវត្ថុដែលអ្នកអាចទទួលបាន។

## ព័ត៌មានជាក់លាក់អំពីករណីឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងអ្នក

*អ្នកមានសិទ្ធិ...*

» ទទួលបានការធ្វើបច្ចុប្បន្នភាពអំពីដំណើរវិវត្តសំខាន់ៗនៅក្នុងសំណុំរឿងនេះ។

» ទទួលបានការដំណឹងទាន់ពេលវេលាអំពីការផ្លាស់ប្ដូរណាមួយនៃកាលវិភាគបង្ហាញខ្លួនក្នុងតុលាការដែលអ្នកត្រូវបានកោះហៅឱ្យបង្ហាញខ្លួន។

» ពិភាក្សាជាមួយព្រះរាជអាជ្ញាមុនចាប់ផ្ដើមសំណុំរឿង មុនពេលសំណុំរឿងត្រូវបានច្រានចោល មុនដំណើរការកាត់ក្ដី និងមុនពេលធ្វើអនុសាសន៍អំពីការកាត់ទោស។

» ពិភាក្សាជាមួយព្រះរាជអាជ្ញានៅពេលណាដែលមេធាវីការពារក្ដីស្នើសុំតុលាការដើម្បីទទួលបានកំណត់ត្រាជំងឺផ្លូវចិត្តរបស់អ្នក ឬព័ត៌មានសម្ងាត់ផ្សេងទៀត។

» ត្រូវបានជូនដំណឹងអំពីរបៀបទទួលបានការបញ្ជាក់ដើម្បីទទួលបានព័ត៌មានអំពីជនប្រព្រឹត្ត។

## នៅពេលចូលរួមក្នុងនីតិវិធីតុលាការ

*អ្នកមានសិទ្ធិ...*

» មានវត្តមាននៅគ្រប់ដំណើរការនីតិវិធីជាមួយក្រុមគ្រួសាររបស់អ្នក លុះត្រាតែអ្នកត្រូវផ្ដល់សក្ខីកម្ម ហើយចៅក្រមសម្រេចថា សក្ខីកម្មរបស់អ្នកអាចរងផលប៉ះពាល់ប្រសិនបើអ្នកមានវត្តមាននៅក្នុងបន្ទប់សវនាការ។

» កន្លែងរង់ចាំសុវត្ថិភាព ឬបន្ទប់ដែលផ្ដល់ដោយតុលាការដែលស្ថិតនៅដាច់ដោយឡែកពីក្រុមគ្រួសារ និងមិត្តភក្ដិរបស់ចុងចោទ និងចុងចោទ។

» ជំនួយពីការិយាល័យព្រះរាជអាជ្ញាជាមួយនិយោជក ឬម្ចាស់បំណុលរបស់អ្នក ប្រសិនបើបទឧក្រិដ្ឋ ឬការចូលរួមរបស់អ្នកនៅក្នុងនីតិវិធីតុលាការបណ្ដាលឱ្យមានបញ្ហាក្នុងការបំពេញការងារ ឬកាតព្វកិច្ចបង់ប្រាក់។ សាក្សីដែលត្រូវបានកោះហៅឱ្យផ្ដល់សក្ខីកម្មនៅក្នុងតុលាការដែលជូនដំណឹងដល់និយោជករបស់ពួកគេជាមុន មិនអាចត្រូវបានបណ្ដេញចេញពីការងារ ឬរងការពិន័យពីសំណាក់និយោជករបស់ខ្លួនដោយសារតែខ្លួនអវត្តមានពីការងារដើម្បីចូលរួមក្នុងនីតិវិធីតុលាការស្របទៅតាម ដីកានេះ។

» នាំយករូបភាពទំហំ 8 x 10 ឬតូចជាងនេះ នៃមនុស្សជាទីស្រលាញ់របស់អ្នក ដែលជាជនរងគ្រោះដោយសារអំពើមនុស្សឃាត ចូលក្នុងបន្ទប់សវនាការ ដរាបណាគណៈវិនិច្ឆ័យមើលមិនឃើញរូបភាពនោះ។

## មុនពេលតុលាការកាត់ទោសចុងចោទ

*អ្នកមានសិទ្ធិ...*

» ពិភាក្សាជាមួយព្រះរាជអាជ្ញាអំពីអនុសាសន៍កាត់ទោសដែលបានស្នើទៅតុលាការ។

» ពិភាក្សាជាមួយមន្ត្រីព្យួរទោសមានលក្ខខណ្ឌ អំពីថាតើឧក្រិដ្ឋកម្មនេះបានប៉ះពាល់ដល់អ្នកយ៉ាងដូចម្ដេចខ្លះ មុនពេលដែលមន្ត្រីនោះដាក់របាយការណ៍ពេញលេញអំពីជនប្រព្រឹត្តជូនតុលាការ។

» ផ្ដល់សេចក្ដីថ្លែងការណ៍អំពីផលប៉ះពាល់មកលើជនរងគ្រោះទៅកាន់តុលាការនៅពេលកាត់ទោសអំពីផលប៉ះពាល់លើរូបរាងកាយ អារម្មណ៍ និងហិរញ្ញវត្ថុដោយសារតែបទល្មើសដែលបានប្រព្រឹត្តមកលើអ្នក និងអំពីការយល់ឃើញរបស់អ្នកអំពីការកាត់ទោសដែលត្រូវធ្វើឡើង។

» ស្នើឱ្យចៅក្រមបង្គាប់ជនប្រព្រឹត្តឱ្យផ្ដល់សំណងសម្រាប់ការខាតបង់ទឹកប្រាក់របស់អ្នកពាក់ព័ន្ធនឹងបទល្មើស និងទទួលបានច្បាប់ចម្លងនៃកាលវិភាគទូទាត់សងរបស់ជនប្រព្រឹត្តពីសំណាក់មន្ត្រីព្យួរទោសមានលក្ខខណ្ឌរបស់ជនប្រព្រឹត្ត។

## ការកាត់ទោស ការប្រគល់សង និងការដោះលែងឬស្ថានភាពជាប់ឃុំរបស់ជនប្រព្រឹត្ត

*អ្នកមានសិទ្ធិ...*

» ទទួលបានការជូនដំណឹងអំពីលទ្ធផលចុងក្រោយនៃសំណុំរឿងរួមទាំងការពន្យល់អំពីប្រភេទនៃទោសដែលបានផ្ដល់ជូន និងច្បាប់ចម្លងនៃលក្ខខណ្ឌការព្យួរទោសសាកល្បង ប្រសិនបើមាន។

» ទទួលបានការជូនដំណឹងពីសំណាក់មន្ត្រីព្យួរទោសមានលក្ខខណ្ឌរបស់ជនប្រព្រឹត្ត នៅពេលណាដែលជនប្រព្រឹត្តសុំផ្លាស់ប្ដូរដីកាផ្ដល់សំណង និងទទួលបានការកោះហៅឱ្យចូលរួមនៅក្នុងសវនាការពាក់ព័ន្ធ។

» ទទួលបានការប្រគល់ទ្រព្យសម្បត្តិរបស់អ្នកដែលបានយកជាភស្ដុតាងមកប្រគល់ជូនអ្នកវិញឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន នៅពេលដែលការអនុវត្តច្បាប់លែងត្រូវការវត្ថុនោះទៀត។

» ប្រសិនបើមានសិទ្ធិ ទទួលបានព័ត៌មានបន្ថែមអំពីជនប្រព្រឹត្តដូចជាកំណត់ត្រាថ្កោលទោស ឬការអនុលោមតាមលក្ខខណ្ឌនៃការកាត់ទោសរបស់ជនប្រព្រឹត្ត។

## ការកាត់ទោស ការប្រគល់សង និងការដោះលែងជនប្រព្រឹត្ត ត....

*អ្នកមានសិទ្ធិ...*

» ទទួលបានការជូនដំណឹងពីក្រុមប្រឹក្សាដោះលែងមានលក្ខខណ្ឌអំពី សិទ្ធិទទួលបានការដោះលែងរបស់ជនប្រព្រឹត្ត។

» ទទួលបានការជូនដំណឹងនៅមុនពេលជនប្រព្រឹត្តត្រូវបានផ្លាស់ប្ដូរទៅមណ្ឌលកែប្រែដែលមិនសូវមានសុវត្ថិភាព។

» ទទួលបានករជូនដំណឹងមុនពេលជនប្រព្រឹត្តទទួលបានការដោះលែងបណ្ដោះអាសន្ន ឬស្ថាពរ ឬរត់ចេញពីមន្ទីរឃុំឃាំង។

## ការកាត់ទោស ការប្រគល់សង និងការដោះលែងឬស្ថានភាពជាប់ឃុំរបស់ជនប្រព្រឹត្ត

*អ្នកមានសិទ្ធិ...*

» ដាក់ពាក្យសុំសំណងជនរងគ្រោះពីឧក្រិដ្ឋកម្មហិង្សាដើម្បីពិនិត្យមើលថាតើអ្នកមានសិទ្ធិទទួលបានសំណងសម្រាប់ការចំណាយផ្ទាល់ខ្លួនអ្វីខ្លះ ដូចជាថ្លៃព្យាបាល ការប្រឹក្សា ឬចំណាយបុណ្យសព ឬបាត់បង់ប្រាក់ឈ្នួលដោយសារពិការភាពដែលបណ្ដាលមកពីឧក្រិដ្ឋកម្ម។

» ស្នើថា ក្នុងអំឡុងនីតិវិធីតុលាការ ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានរបស់អ្នកអំពីអាសយដ្ឋានស្នាក់នៅ លេខទូរស័ព្ទ សាលារៀន និងទីកន្លែងធ្វើការរបស់សមាជិកគ្រួសារមិនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឡើយ។

» ការការពារជាក់លាក់តាមរយៈមន្ត្រីអនុវត្តច្បាប់ ពីការខូចខាតឬការគំរាមកំហែងនៃការខូចខាតបណ្ដាលមកពីកិច្ចសហប្រតិបត្តិការរបស់អ្នកនៅក្នុងនីតិវិធីតុលាការ។

» ការចាត់ចែងភ្លាមៗនូវសំណុំរឿងព្រហ្មទណ្ឌពាក់ព័ន្ធនឹងអ្នក។

» ដាក់ស្នើ ឬបដិសេធមិនចូលរួមក្នុងកិច្ចសម្ភាសន៍ជាមួយក្រុមមេធាវីការពារក្ដី មុនពេលកាត់ក្ដី ឬកំណត់លក្ខខណ្ឌសមហេតុផលលើការសម្ភាសន៍ទាំងនេះ ប្រសិនបើអ្នកសម្រេចទទួលយកការសម្ភាសន៍។

» ប្រសិនបើអាច សូមពិគ្រោះជាមួយមេធាវីឯកជន ដើម្បីចាប់ផ្ដើមបណ្ដឹងរដ្ឋប្បវេណីដោយខ្លួនឯងដើម្បីទាមទារសំណងសម្រាប់ការខូចខាតដោយសារបទល្មើស។